# វេទិកាគោលនយោបាយ ថ្នាក់ខេត្ត

## សារៈសំខាន់នៃការស្រាវជ្រាវនៅថ្នាក់ក្រោមជាតិ ក្នុងការឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩



ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២

ខេត្តបាត់ដំបង ព្រះរាជាណាចក្រកម្ពុជា

# វេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ

សារៈសំខាន់នៃការស្រាវជ្រាវនៅថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបទៅ
នឹងវិបត្តិកូវីដ-១៩

ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២២
ខេត្តបាត់ដំបង ព្រះរាជាណាចក្រកម្ពុជា

Australian Aid

ពន្លកចំណេះ

The Asia Foundation

# មាតិកា

សេចក្តីថ្លែងអំណរគុណ.......................................................................................i
អំពីអ្នករៀបចំកម្មវិធី.......................................................................................ii
សេចក្តីផ្តើម.......................................................................................១
ការប្រើប្រាស់ទិន្នន័យដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្ត ៖ ការប្រើប្រាស់ទិន្នន័យរបស់រដ្ឋបាលមូលដ្ឋានដើម្បីឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ក្នុងអំឡុងពេលវិបត្តិកូវីដ-១៩.......................................................................................៣
ផលប៉ះពាល់នៃវិបត្តិកូវីដ -១៩ ទៅលើសេដ្ឋកិច្ចសង្គមរបស់ប្រជាជនក្នុងតំបន់និងសហគមន៍ជនជាតិដើមភាគតិច ៖ ករណីសិក្សាពីខេត្តស្ទឹងត្រែង .......................................................................................៥
បញ្ហាប្រឈមក្នុងការរៀនសូត្រ និងការបោះបង់ការសិក្សារបស់កុមារក្នុងអំឡុងពេលវិបត្តិកូវីដ-១៩ ៖ ករណីសិក្សាពីខេត្តក្រចេះ .......................................................................................៩
ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើកិច្ចគាំពារ និងសុខុមាលភាពកុមារ ៖ ករណីសិក្សាពីខេត្តបាត់ដំបង.......................................................................................១២
សេចក្តីសន្និដ្ឋាន.......................................................................................១៦
របៀបវារៈ.......................................................................................១៩

## សេចក្តីថ្លែងអំណរគុណ

អង្គការមូលនិធិអាស៊ីសូមថ្លែងអំណរគុណចំពោះការរួមចំណែករបស់ ស្ថាប័នពាក់ព័ន្ធនានា និងម្ចាស់ជំនួយ ដែលបានធ្វើឱ្យវេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ អាចដំណើរការទៅបានដោយរលូន។

អង្គការមូលនិធិអាស៊ីក៏សូមអរគុណអង្គការដៃគូស្រាវជ្រាវដែលបានផ្តល់ធាតុចូល និងចូលរួមសហការក្នុងការរៀបចំកិច្ចពិភាក្សាពេញអង្គ និងអរគុណវាគ្មិន និងអ្នកសម្របសម្រួលដែលបានផ្តល់មតិយោបល់ ក្នុងអំឡុងកិច្ចពិភាក្សា ក៏ដូចជាអរគុណក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលីដែលបានផ្តល់ជំនួយថវិកា។

## អំពីកម្មវិធីពន្លកចំណេះ

កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា ជាគំនិតផ្តួចផ្តើមរយៈពេល ៥ឆ្នាំ (២០១៩-២០២៣) ដែលមានគោលបំណងពង្រឹងវិស័យស្រាវជ្រាវ និងគាំទ្រដល់ការវិភាគ និងពិភាក្សាអំពីគោលនយោបាយសាធារណៈនៅកម្ពុជា។ ដោយទទួលបានការគាំទ្រពី ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី អង្គការមូលនិធិអាស៊ីមានគោលបំណងពង្រឹងសមត្ថភាពផ្នែកស្ថាប័ន និងផ្នែកបច្ចេកទេសរបស់ស្ថាប័នស្រាវជ្រាវនៅកម្ពុជា និងបង្កើតបរិយាកាសអំណោយផលសម្រាប់ការពិភាក្សាគោលនយោបាយ។

## អំពីអង្គការមូលនិធិអាស៊ី

អង្គការមូលនិធិអាស៊ី ជាអង្គការអភិវឌ្ឍន៍អន្តរជាតិមិនស្វែងរកប្រាក់ចំណេញ ដែលប្តេជ្ញាលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់អាស៊ី។ផ្អែកតាមបទពិសោធន៍និងជំនាញជាង ៦ ទសវត្សរ៍ ការងាររបស់អង្គការមូលនិធិអាស៊ី នៅតំបន់អាស៊ីផ្តោតសំខាន់លើ អភិបាលកិច្ចល្អ ការបង្កើនភាពអង់អាចរបស់ស្ត្រី និងសមភាពយេនឌ័រ កំណើនសេដ្ឋកិច្ចបរិយាបន្ន សកម្មភាពបរិស្ថាន និងអាកាសធាតុ និងទំនាក់ទំនងក្នុងតំបន់ និងអន្តរជាតិ។

# អំពីអ្នករៀបចំកម្មវិធី

### ក្រុមការងារអង្គការមូលនិធិអាស៊ី

ជា លីម៉េង

ជា យ៉ន

ឌីយ៉ា ណាក់

មេឡូនី លីនប៊ឹក

ម៉ែន ពិចិត្រ

មិន សំនាង

ម្លូក ម៉ាអេឡេន

ងិន ពិសិដ្ឋ

ភួង សុធីនី

ប្រាក់ វត្តិធីរា

សារ៉េត ស្រីស្រស់

សារី ភីរម្យ

### អង្គការដៃគូស្រាវជ្រាវរបស់កម្មវិធីពន្លកចំណេះ

សមាគមខ្មែរដើម្បីអភិវឌ្ឍន៍តាមជនបទ

សមាគមកុមាររីករាយ

អង្គការភូមិខ្ញុំ

### ជំនួយថវិកា

កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា ទទួលបានការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី និងអនុវត្តដោយអង្គការមូលនិធិអាស៊ី។

### អំណះអំណាង៖

វេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ ស្តីពី «សារៈសំខាន់នៃការស្រាវជ្រាវនៅថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបទៅនឹងវិបត្តិកូវីដ -១៩ » ទទួលបានការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី តាមរយៈកម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា របស់អង្គការមូលនិធិអាស៊ី។ ទស្សនៈដែលលើកឡើងក្នុងសៀវភៅនេះគឺជាទស្សនៈរបស់វាគ្មិនផ្ទាល់ ពោលគឺមិនបានឆ្លុះបញ្ចាំងពីទស្សនៈ និងការយល់ឃើញរបស់រដ្ឋាភិបាលអូស្ត្រាលី និងអង្គការមូលនិធិអាស៊ីឡើយ។

©អង្គការមូលនិធិអាស៊ី ២០២២




Ponlok Chomnes Provincial Policy Forum
"Local Knowledge Matters:











# សេចក្តីផ្តើម

ជាងពីរឆ្នាំកន្លងមកនេះ ជំងឺរាតត្បាតជាសកលកូវីដ-១៩ បានដាក់សម្ពាធយ៉ាងខ្លាំងលើវិស័យជាច្រើននៅកម្ពុជា ដោយបានពន្យឺតការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសនេះ ។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់ភាគីពាក់ព័ន្ធ ដូចជា រដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាប្រឈមដែលកើតចេញពីជំងឺរាតត្បាតនេះក៏ដោយ ក៏បញ្ហាប្រឈមទាំងនោះនៅតែបង្កផលប៉ះពាល់លើក្រុមមួយចំនួន។

ក្រុមងាយរងគ្រោះនៅកម្ពុជានៅតែប្រឈមនឹងការលំបាក និងឧបសគ្គក្នុងការបន្សាំខ្លួនទៅនឹងការផ្លាស់ប្តូរនៃបរិបទនាពេលបច្ចុប្បន្ន និងខិតខំរិះរកវិធីស្តារឡើងវិញពីផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលនៃជំងឺរាតត្បាតនេះ។ ជំងឺកូវីដ-១៩ បានរឹតត្បិតលទ្ធភាពរបស់ក្រុមទាំងនេះក្នុងការទទួលបានធនធានចាំបាច់ និងតម្រូវការមូលដ្ឋាន។ ឧទាហរណ៍ កុមារងាយប្រឈមនឹងបញ្ហាសុខភាព កង្វះអាហារូបត្ថម្ភ និងការអប់រំដែលមានគុណភាព។ ក្រៅពីនេះ ជំងឺកូវីដ-១៩ ធ្វើឱ្យប៉ះពាល់ដល់ការជួបជុំរបស់ប្រជាពលរដ្ឋដែលបានជះផលអវិជ្ជមានលើសេដ្ឋកិច្ចសង្គម ។ ចំនួននៃការឆ្លងជំងឺកូវីដ-១៩មានការថយចុះជាបន្តបន្ទាប់និងយ៉ាងឆាប់រហ័សនៅកម្ពុជាដែលក្នុងនោះប្រជាជនកម្ពុជាយ៉ាងច្រើនបានចាក់វ៉ាក់សាំង ប៉ុន្តែកូវីដ-១៩ បានបន្សល់នូវមេរៀនសំខាន់ៗមួយចំនួនស្តីពីបរិយាបន្នសង្គម។ ការត្រៀមជាស្រេច និងអនុសាសន៍គ្រប់ជ្រុងជ្រោយដើម្បីបន្តកិច្ចខិតខំប្រឹងប្រែងរបស់តួអង្គសំខាន់ៗ នឹងជួយដល់ការស្តារឡើងវិញ និងការវិនិយោគនាពេលអនាគតនៅកម្ពុជា។

កម្មវិធីពន្លកចំណេះ បានគាំទ្រដល់អង្គការដៃគូស្រាវជ្រាវរបស់ខ្លួនដែលធ្វើការសិក្សាស្រាវជ្រាវលើផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើវិស័យជាច្រើន ដូចជា ផលប៉ះពាល់នៃជំងឺកូវីដ-១៩លើក្រុមងាយរងគ្រោះ ជាអាទិ៍កុមារ និងជនជាតិដើមភាគតិចនៅកម្ពុជា។ ការស្រាវជ្រាវនេះបានផ្តល់ព័ត៌មាន និងទិន្នន័យតាមមូលដ្ឋាន និងរួមចំណែកដល់ការបង្កើន និងពង្រឹងចំណេះដឹងស្តីពីផលប៉ះពាល់ជាក់ស្តែងនៃជំងឺរាតត្បាតជាសកលនេះលើប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន។

ខណៈដែលទិន្នន័យថ្នាក់ជាតិ មានសារៈសំខាន់សម្រាប់ការតាក់តែងគោលនយោបាយថ្នាក់ជាតិ ចំណេះដឹង និងទិន្នន័យថ្នាក់មូលដ្ឋានមានសារៈសំខាន់សម្រាប់គាំទ្រដល់អន្តរាគមន៍លើបញ្ហាដែលកើតឡើងនៅថ្នាក់មូលដ្ឋាន ដើម្បីឱ្យស្របតាមតម្រូវការរបស់ប្រជាជនក្នុងមូលដ្ឋានផ្ទាល់។ ដូច្នេះ កម្មវិធីពន្លកចំណេះ បានសហការជាមួយអង្គការដៃគូស្រាវជ្រាវ ដូចជាសមាគមខ្មែរដើម្បីអភិវឌ្ឍន៍តាមជនបទ សមាគមកុមាររីករាយ និងអង្គការភូមិខ្ញុំ រៀបចំវេទិកាគោលនយោបាយថ្នាក់ខេត្ត ដើម្បីស្វែងរកការចូលរួមពីតំណាងរដ្ឋាភិបាលថ្នាក់ខេត្ត អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក(NGOs) ក៏ដូចជាស្ថាប័ននានា ដើម្បីបង្ហាញពីលទ្ធផលស្រាវជ្រាវ ពិភាក្សាចែករំលែកចំណេះដឹង និងកសាង បណ្តាញជាមួយអ្នកប្រើប្រាស់ការស្រាវជ្រាវ រួមមាន អ្នកតាក់តែងគោលនយោបាយ និងអ្នកអនុវត្តគោលនយោបាយនៅថ្នាក់ខេត្ត (ដូចជា តំណាងមកពីខេត្តបាត់ដំបង ក្រចេះ និងស្ទឹងត្រែង)។

គោលបំណងនៃវេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ រួមមានការបង្ហាញលទ្ធផលនៃការស្រាវជ្រាវ និងទិន្នន័យដែលឆ្លើយតបនឹងតម្រូវការគោលនយោបាយឆ្លើយតបនឹងវិបត្តិកូវីដ-១៩ នៅថ្នាក់ក្រោមជាតិនៅក្នុងប្រទេសកម្ពុជា ការលើកកម្ពស់ការចែករំលែកចំណេះដឹង និងការពិភាក្សាគោលនយោបាយដោយអ្នកតាក់តែងគោលនយោបាយ និងដៃគូពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការបង្កើតបរិយាកាសអំណោយផលសម្រាប់តួអង្គក្នុងវិស័យស្រាវជ្រាវដើម្បីជួបពិភាក្សា និងពង្រីក បណ្តាញទំនាក់ទំនងដើម្បីកសាងសហគមន៍ស្រាវជ្រាវដ៏រឹងមាំនៅថ្នាក់ខេត្ត។

សៀវភៅស្តីពីវេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ ស្តីពី «សារៈសំខាន់នៃការស្រាវជ្រាវនៅថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩»ចែកចេញជា ៦ ផ្នែក ដូចជា សេចក្តីផ្តើម កិច្ចពិភាក្សាពេញអង្គស្តីពី «ការប្រើប្រាស់ទិន្នន័យដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្ត៖ ការប្រើប្រាស់ទិន្នន័យរបស់រដ្ឋបាលមូលដ្ឋានដើម្បីឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ក្នុងអំឡុងពេលវិបត្តិកូវីដ-១៩» កិច្ចពិភាក្សាស្តីពី «បញ្ហាប្រឈមក្នុងការរៀនសូត្រ និងការបោះបង់ការសិក្សារបស់កុមារក្នុងអំឡុងពេលវិបត្តិកូវីដ-១៩៖ ករណីសិក្សាពីខេត្តក្រចេះ» «ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ ទៅលើសេដ្ឋកិច្ចសង្គមរបស់ប្រជាជនក្នុងតំបន់ និងសហគមន៍ជនជាតិដើមភាគតិច៖ ករណីសិក្សាពីខេត្តស្ទឹងត្រែង» «ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើកិច្ចគាំពារនិងសុខុមាលភាពកុមារ៖ ករណីសិក្សាពីខេត្តបាត់ដំបង»និងសេចក្តីសន្និដ្ឋាន។



# ការប្រើប្រាស់ទិន្នន័យដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្ត៖ ការប្រើប្រាស់ទិន្នន័យរបស់រដ្ឋបាលមូលដ្ឋានដើម្បីឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ក្នុងអំឡុងពេលវិបត្តិកូវីដ-១៩




រយៈពេលពីរឆ្នាំកន្លងមកនេះ វីរុសកូរ៉ូណាបានដាក់បន្ទុកយ៉ាងខ្លាំងលើប្រព័ន្ធសុខភាពសាធារណៈនៅកម្ពុជា។ ទោះជាយ៉ាងណា កម្ពុជានៅតែអាចគ្រប់គ្រងស្ថានភាពជំងឺកូវីដ-១៩បានតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីចាក់វ៉ាក់សាំង និងការកសាងសមត្ថភាពក្នុងការឆ្លើយតបយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព។

ជំងឺកូវីដ-១៩បានបង្កផលប៉ះពាល់លើជីវភាពរស់នៅរបស់ប្រជាជនក្នុងមូលដ្ឋានរួមទាំងក្រុមដែលត្រូវបានគេមើលរំលង និងក្រុមងាយរងគ្រោះ ដោយពួកគេជួបប្រទះនឹងការបាត់បង់ប្រាក់ចំណូល ភាពដុនដាបផ្នែកសេដ្ឋកិច្ច និងបញ្ហាសុខភាព។ រដ្ឋាភិបាល និងគោលនយោបាយជាតិ បានផ្តល់ការណែនាំ និងដាក់ទិសដៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រងការរាតត្បាតនៃជំងឺកូវីដ -១៩ និងបានផ្តល់សេវាចាំបាច់ដល់ប្រជាជនងាយរងគ្រោះ។ ជាឧទាហរណ៍ អាជ្ញាធរមូលដ្ឋានបានសម្របសម្រួលការចែកស្បៀងអាហារ ការទទួលបានសេវាសុខភាពសំខាន់ៗ និងសេវាផ្សេងទៀតក្នុងសហគមន៍មូលដ្ឋាន ក៏ដូចជាជួយដល់រដ្ឋាភិបាលថ្នាក់ជាតិក្នុងការកំណត់អត្តសញ្ញាណប្រជាជន ដែលមានលក្ខណៈសម្បត្តិចូលរួមក្នុងកម្មវិធីសុខុមាលភាពសង្គមរបស់កម្ពុជា អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់។

## ខ្លឹមសារសង្ខេបនៃកិច្ចពិភាក្សា

ចំណេះដឹង និងទិន្នន័យថ្នាក់មូលដ្ឋានមានសារៈសំខាន់សម្រាប់ការកំណត់រកបញ្ហាដែលលេចឡើងនៅកម្រិតមូលដ្ឋាន តាមរយៈការរួមចំណែកអន្តរាគមន៍របស់អាជ្ញាធរមូលដ្ឋានដែលត្រូវបានកែសម្រួលទៅតាមតម្រូវការរបស់ប្រជាជនក្នុងមូលដ្ឋានផ្ទាល់។ កិច្ចពិភាក្សាពេញអង្គស្តីពី «ការប្រើប្រាស់ទិន្នន័យដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តៈ ការប្រើប្រាស់ទិន្នន័យរបស់រដ្ឋបាលមូលដ្ឋានដើម្បីឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ក្នុងអំឡុងពេលវិបត្តិកូវីដ-១៩» ផ្អែកលើមតិយោបល់របស់ភាគីពាក់ព័ន្ធសំខាន់ៗមកពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដើម្បីឆ្លើយតបនឹងជំងឺកូវីដ-១៩ រដ្ឋាភិបាលថ្នាក់ជាតិ ក៏ដូចជារដ្ឋបាលថ្នាក់មូលដ្ឋាន បានប្រើប្រាស់មូលដ្ឋានទិន្នន័យឃុំ មូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ID-Poor) និងធនធានបែបបរិមាណផ្សេងទៀតដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីស្វែងយល់កាន់តែច្បាស់អំពីស្ថានភាពក្នុងមូលដ្ឋាន ដូចជា ស្ថានភាពហិរញ្ញវត្ថុ ស្ថានភាពទេសន្តរប្រវេសន៍ និងបម្រែបម្រួលផ្សេងទៀត។ ក្រៅពីនេះ ទិន្នន័យថ្នាក់មូលដ្ឋានជួយដល់ការកំណត់អត្តសញ្ញាណគ្រួសារដែលធ្លាក់ក្រោមបន្ទាត់ភាពក្រីក្រដែលកំណត់ដោយរដ្ឋាភិបាល ដើម្បីឱ្យពួកគេអាចទទួលបានអត្ថប្រយោជន៍ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់របស់រដ្ឋាភិបាល ក្នុងអំឡុងពេលវិបត្តិកូវីដ-១៩។ ទិន្នន័យទាំងនេះក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរក្នុងការជួយដល់រដ្ឋាភិបាលលើការអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងនៅថ្នាក់មូលដ្ឋាន ដែលបានរួមចំណែកដល់ការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងនាំឱ្យមានការបើកប្រទេសឡើងវិញសម្រាប់ការស្តារសេដ្ឋកិច្ច។

ក្នុងការប្រមូលទិន្នន័យទាំងនេះ រដ្ឋបាលមូលដ្ឋានបានសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលថ្នាក់ជាតិដើម្បីធានាការប្រមូល ការប្រើប្រាស់ និងការចែករំលែកទិន្នន័យទាំងនេះមានប្រសិទ្ធភាព។ រដ្ឋបាល ថ្នាក់មូលដ្ឋានប្រើប្រាស់មធ្យោបាយច្រើនបែប ក្នុងការប្រមូលទិន្នន័យ ពោលគឺប្រើប្រាស់ទាំងទម្រង់ឌីជីថល និងទម្រង់លើក្រដាស)។ ទោះជាយ៉ាងណា ការប្រមូលទិន្នន័យប្រឈមបញ្ហាមួយចំនួន ជាពិសេស សំណេរដោយដៃ ឬការប្រើប្រាស់ក្រដាសដែលមានភាពយឺត





# ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ ទៅលើសេដ្ឋកិច្ចសង្គមរបស់ប្រជាជនក្នុងតំបន់ និងសហគមន៍ជនជាតិដើមភាគតិច៖ ករណីសិក្សាពីខេត្តស្ទឹងត្រែង




ជំងឺរាតត្បាតសកលកូវីដ-១៩ បង្កផលប៉ះពាល់លើសកលលោកទាំងមូល ព្រោះវាបានឆ្លងរាលដាលទៅគ្រប់ទ្វីបទាំងអស់។ ក្នុងតំបន់មេគង្គ ជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់លើពលករទេសន្តរប្រវេសន៍ កម្មករកាត់ដេរ ជនជាតិដើមភាគតិច និងជនជាតិភាគតិច ជនត្រូវបានផ្លាស់ទីលំនៅក្នុងស្រុក ឬជនទេសន្តរប្រវេសន៍ អ្នករស់នៅក្នុងសំណង់អនាធិបតេយ្យនៅទីប្រជុំជន និងអ្នកធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជា អ្នកប្រកបរបរផ្លូវភេទ (CARE, 2020)។

នៅកម្ពុជា អង្គការវេទិកាអនាគត និងក្រុមហ៊ុនអង្គរស្រាវជ្រាវ និងប្រឹក្សា បានស្ទង់មតិក្នុងឆ្នាំ ២០២០ ស្តីពីផលប៉ះពាល់នៃជំងឺកូវីដ-១៩លើប្រទេសកម្ពុជា។ ការស្រាវជ្រាវនេះរួមបញ្ចូលគំហើញស្តីពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃជំងឺកូវីដ-១៩ ផលប៉ះពាល់លើអ្នកធ្វើការដែលទទួលបានប្រាក់ឈ្នួល ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើកសិករ អាជីវកម្មលក្ខណៈគ្រួសារ ក៏ដូចជាការសន្សំប្រាក់ និងបំណុល។ ខណៈដែលការស្ទង់មតិទាំងនោះផ្តោតសំខាន់លើទិន្នន័យបែបបរិមាណ និងផ្តល់ទិដ្ឋភាពធំទូលាយស្តីពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើគ្រួសារងាយរងគ្រោះ ការស្រាវជ្រាវដោយអង្គការភូមិខ្ញុំ ផ្តោតសំខាន់លើសហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តស្ទឹងត្រែង។

ការស្រាវជ្រាវរបស់អង្គការភូមិខ្ញុំគូសបញ្ជាក់ថា ជំងឺកូវីដ-១៩បានបង្កផលប៉ះពាល់អវិជ្ជមានលើជីវភាពរស់នៅ ការងារ និងប្រាក់ចំណូល ការអប់រំ ការធ្វើចំណាកស្រុក សុខភាព និងធនធានធម្មជាតិរបស់ជនជាតិដើមភាគតិច។ ជនជាតិដើមភាគតិចជាច្រើនប្រឈមនឹងការលំបាកផ្នែកសេដ្ឋកិច្ចដោយសារជំងឺកូវីដ-១៩។ ឧទាហរណ៍ តម្លៃត្រីធ្លាក់ថ្លៃដោយសារតម្រូវការថយចុះ និងការបង្អាក់សង្វាក់តម្លៃដែលជះផលអវិជ្ជមានលើការរកប្រាក់ចំណូលរបស់អ្នកនេសាទត្រីដែលជាអ្នកលក់ត្រីផ្ទាល់។ ទន្ទឹមនឹងនេះ ពលករទេសន្តរប្រវេសន៍បានត្រឡប់មកស្រុកវិញ ដោយសារ

ការព្រួយបារម្ភពីសុខភាពផ្ទាល់ខ្លួន។ ដូច្នេះ ពួកគេភាគច្រើនត្រូវបាត់បង់ការងារ។ សាលារៀនត្រូវបានបិទដោយសារជំងឺកូវីដ-១៩ ដែលនាំឱ្យមានការកើនឡើងនៃវិសមភាពក្នុងការអប់រំ។ វិស័យសុខាភិបាលក៏រងផលប៉ះពាល់ផងដែរ ព្រោះប្រជាជនមានការលំបាកក្នុងការទទួលបានសេវាសុខភាព ក្រោមការរឹតត្បិតការធ្វើដំណើរ។ ជនទេសន្តរប្រវេសន៍មួយចំនួនដែលត្រឡប់មកស្រុកកំណើតវិញបានងាកទៅពឹងផ្អែកលើធនធានព្រៃឈើ និងជលផល ដូច្នេះ វិបត្តិកូវីដ-១៩ បានបន្ថែមសម្ពាធលើធនធានធម្មជាតិ។

កិច្ចពិភាក្សាពេញអង្គស្តីពី «ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ ទៅលើសេដ្ឋកិច្ចសង្គមរបស់ប្រជាជនក្នុងតំបន់ និងសហគមន៍ជនជាតិដើមភាគតិចៈ ករណីសិក្សាពីខេត្តស្ទឹងត្រែង» ពិភាក្សាគំហើញពីការស្រាវជ្រាវរបស់អង្គការភូមិខ្ញុំ ដែលអាចយកទៅពិចារណាដើម្បីដាក់បញ្ចូលទៅក្នុងផែនការស្តារ ឡើងវិញរបស់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន មន្ទីរពាក់ព័ន្ធ អង្គការសង្គមស៊ីវិល (CSO) ក្រុមប្រឹក្សាឃុំ និងសហគមន៍មូលដ្ឋាន។



## ខ្លឹមសារសង្ខេបនៃកិច្ចពិភាក្សា

ការស្ទង់មតិដែលធ្វើឡើងដោយអង្គការភូមិខ្ញុំស្ដីពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើសហគមន៍ជនជាតិដើមភាគតិច បង្ហាញថា ប្រាក់ចំណូលរបស់ប្រជាជនក្នុងសហគមន៍មានការថយចុះនៅអំឡុងនៃការផ្ទុះឡើងជំងឺកូវីដ-១៩ ដោយសារតែពួកគេមិនអាចលក់កសិផល និងផលនេសាទក្រោមការរឹតត្បិតការធ្វើដំណើរ។ អ្នកធ្វើការនៅក្រៅសហគមន៍ដែលបាត់បង់ការងារបានវិលត្រឡប់មករស់នៅជួបជុំក្រុមគ្រួសារក្នុងសហគមន៍ និងស្វែងរកការងារក្នុងមូលដ្ឋាន។ ការដាក់សម្ពាធភ្លាមៗលើសេដ្ឋកិច្ចមូលដ្ឋាន បានបង្កើនការប្រជែងដណ្ដើមឱកាសការងារដែលមានតិចតួច។ អ្វីដែលជាលទ្ធផលវិជ្ជមានគឺ ប្រជាជនលើកឡើងថា ពួកគេគិតគូរពីសុខភាពផ្ទាល់ខ្លួនជាងមុន។ ពួកគេដឹងពីរបៀបការពារខ្លួនដោយលាងសម្អាតដៃញឹកញាប់ និងពាក់ម៉ាស់។

គួរឱ្យសោកស្ដាយ ដែលមូលដ្ឋានសុខាភិបាលឯកជនមួយចំនួនស្ទាក់ស្ទើរមិនហ៊ានទទួលអ្នកជំងឺ ដោយភ័យខ្លាចការឆ្លងរាលដាលជំងឺកូវីដ-១៩។ ការរៀនសូត្ររបស់សិស្សក៏ចោទជាបញ្ហាផងដែរ។ ដោយសារការបិទសាលារៀន ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្ដើមប្រើប្រាស់វីដេអូមេរៀនដែលសិស្សអាចចូលមើលតាមទូរទស្សន៍ និងកម្មវិធីក្នុងទូរស័ព្ទចល័ត។ ទោះជាយ៉ាងណា សិស្សជាច្រើនមិនអាចចូលមើលវីដេអូទាំងនោះបានទេ។ ក្រៅពីនេះ សិស្សដែលជាជនជាតិដើមភាគតិចលំបាកក្នុងការរៀនសូត្រតាមវីដេអូ ព្រោះវីដេអូបង្រៀនទាំងអស់សុទ្ធតែនិយាយភាសាខ្មែរ។ ទោះបីជាមានការចែកសំណៅឯកសារកិច្ចការផ្ទះដល់សិស្សក៏ដោយ ក៏ជារឿយៗ សិស្សមិនសូវទទួលបានការជ្រោមជ្រែងនៅផ្ទះ ឬក្នុងសហគមន៍នោះទេ នៅពេលពួកគេមានចម្ងល់ ឬត្រូវការជំនួយបន្ថែម។ សិស្សមួយចំនួនជួយធ្វើស្រែចម្ការជាមួយគ្រួសារក្នុងពេលបិទសាលារៀន។ ដូច្នេះ ពួកគេមិនអាចទទួលបានកិច្ចការសាលានោះទេ។ ការស្ទង់មតិនេះក៏បង្ហាញពីការកើនឡើងនៃអំពើហិង្សាក្នុងគ្រួសារផងដែរ ដោយអ្នកតបសម្ភាសន៍កត់សម្គាល់ថាឪពុកម្ដាយចំណាយពេលនៅផ្ទះច្រើន និងពិសាគ្រឿងស្រវឹង។

ទោះបីជាក្រសួងអប់រំ យុវជន និងកីឡា ខិតខំប្រឹងប្រែងយ៉ាងក៏ដោយ ក៏មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង នៅតែប្រឈមនឹងបញ្ហាមួយចំនួន។ ក្នុងខេត្តនេះ ផ្ទះរបស់សិស្សនៅឆ្ងាយពីគ្នា ហើយគ្រូមិនអាចចូលដល់ផ្ទះរបស់ពួកគេបានទេ ដោយសារស្ថានភាពផ្លូវលំបាកក្នុងតំបន់ដាច់ស្រយាល។ បញ្ហាប្រឈមមួយទៀតគឺគ្រូបង្រៀនដែលជាជនជាតិខ្មែរ មិនអាចធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយសិស្សដែលជាជនជាតិដើមភាគតិច ចំណែកការសិក្សាតាមប្រព័ន្ធអនឡាញគឺគ្មានប្រសិទ្ធភាព ដោយសារសេវាអ៊ីនធឺណិតរអាក់រអួល។

ភ្លាមៗ ក្រោយការផ្ទុះឡើងនៃជំងឺរាតត្បាតសកលកូវីដ-១៩ រដ្ឋបាលខេត្តស្ទឹងត្រែងបានបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ដែលឆ្លើយតបនឹងស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងខេត្ត។ គណៈកម្មាធិការនេះបានប្រែក្លាយមន្ទីរពេទ្យទៅជាមណ្ឌលព្យាបាលជំងឺកូវីដ-១៩ និងមណ្ឌលចត្តាឡីស័ក។ ទន្ទឹមនឹងនេះ រដ្ឋាភិបាលបានចាប់ផ្ដើមចេញលិខិតបញ្ជាក់អត្តសញ្ញាណកម្មគ្រួសារក្រីក្រដល់គ្រួសារងាយរងគ្រោះ ដើម្បីឱ្យពួកគេបានទទួលការឧបត្ថម្ភសាច់ប្រាក់ក្រោម

កម្មវិធីគាំពារសង្គមរបស់រដ្ឋាភិបាល។

នៅពេលដែលស្ថានភាពជំងឺកូវីដ-១៩បានធូរស្រាល យើងគួរពិចារណាពីជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិច។ រដ្ឋាភិបាលគួរផ្តល់កញ្ចប់ជំនួយដើម្បីជួយដល់ជនជាតិដើមភាគតិចដែលជំពាក់បំណុលក្រោមផែនការយុទ្ធសាស្រ្តស្តារឡើងវិញ។ ទន្ទឹមនឹងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីលើកកម្ពស់ការសិក្សារបស់សិស្ស ការកែសម្រួលទៅតាមបរិបទមូលដ្ឋានមានសារៈសំខាន់ណាស់។ យុវជនដែលមានចំណេះដឹងច្រើនក្នុងសហគមន៍គួរជួយគាំទ្រ និងបង្រៀនកុមារតូចដែលមិនសូវមានចំណេះដឹង។ ដោយសារជំងឺរាតត្បាតសកលកូវីដ-១៩បានបង្អាក់ប្រព័ន្ធអប់រំជិតពីរឆ្នាំ ដូច្នេះការវាយតម្លៃលើសមត្ថភាពរបស់សិស្សគួររៀបចំឡើង ដើម្បីរៀបចំផែនការគាំទ្រដល់តម្រូវការរៀនសូត្ររបស់ពួកគេ។ សង្គមស៊ីវិល និងរដ្ឋបាលថ្នាក់មូលដ្ឋាន គួរផ្តល់ការណែនាំដល់ប្រជាជនក្នុងសហគមន៍ស្តីពីរបៀបប្រើប្រាស់បណ្តាញសង្គម ដូចជា Telegram និង Facebook ដើម្បីទទួលបានព័ត៌មានដែលអាចមានប្រយោជន៍សម្រាប់ការអភិវឌ្ឍសហគមន៍របស់ពួកគេ។ ក្រៅពីនេះ រដ្ឋាភិបាលគួរពិចារណាដាក់បញ្ចូលមេរៀនពីគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដើម្បីឱ្យអាជ្ញាធរមូលដ្ឋានត្រៀមខ្លួនទប់ទល់នឹងជំងឺរាតត្បាតជាសកលនាពេលអនាគត។



## អ្នកសម្របសម្រួល



បណ្ឌិត លន់ ពេជ្រតារា
នាយកប្រតិបត្តិ
អង្គការភូមិខ្ញុំ

## វាគ្មិនកិត្តិយស



លោក ញ៉ែម វណ្ណយុត្តិ
នាយក
រដ្ឋបាលខេត្តស្ទឹងត្រែង



លោក សែត ពិសិដ្ឋ
អនុប្រធានការិយាល័យ
មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង



លោក ប៉ោ ណារិទ្ធ
ទីប្រឹក្សា
អង្គការភូមិខ្ញុំ

# បញ្ហាប្រឈមក្នុងការរៀនសូត្រ និងការបោះបង់ការសិក្សារបស់កុមារ ក្នុងអំឡុងពេលវិបត្តិកូវីដ-១៩ ៖ ករណីសិក្សាពីខេត្តក្រចេះ




ក្នុងអំឡុងពេលនៃការបិទសាលារៀនទូទាំងប្រទេសកម្ពុជា គ្រឹះស្ថានអប់រំត្រូវបានតម្រូវឱ្យផ្លាស់ប្តូររបៀបនៃការបង្រៀន និងរៀនក្នុងថ្នាក់ផ្ទាល់ ទៅជាការបង្រៀន និងរៀនតាមប្រព័ន្ធអនឡាញ។ គ្រូបង្រៀន និងបុគ្គលិកសាលារៀន ក៏ទទួលរងផលប៉ះពាល់យ៉ាងខ្លាំងផងដែរ ព្រោះការរឹតត្បិតការជួបជុំជាសាធារណៈបានបង្អាក់ការបណ្តុះបណ្តាលគ្រូបង្រៀន។ គ្រូបង្រៀនត្រូវសម្របខ្លួនទៅតាមមធ្យោបាយបង្រៀនថ្មីៗ ក្នុងរយៈពេលដ៏ខ្លី។

កុមារនៅកម្ពុជាក៏ប្រឈមនឹងបញ្ហាផងដែរ ព្រោះសិស្សកម្រិតបឋមដែលមកពីគ្រួសារមានប្រាក់ចំណូលទាប និងគ្រួសារមានប្រាក់ចំណូលមធ្យម ត្រូវប្រឈមនឹងការលំបាកក្នុងការសិក្សា។ គ្រួសារមួយចំនួនមិនអាចប្រើប្រាស់អ៊ីនធឺណិតបាន ហើយគ្រួសារក្រីក្រជាច្រើនមិនអាចទិញឧបករណ៍អេឡិចត្រូនិកចាំបាច់ ដូចជា ស្មាតហ្វូន និងតាប្លេត ដើម្បីឱ្យកូនបានសិក្សារៀនសូត្រ។ គ្រួសារខ្លះពឹងផ្អែកលើកម្លាំងពលកម្មរបស់កូនដើម្បីរកប្រាក់ចំណូល ឬធ្វើកិច្ចការផ្ទះសម្បែងច្រើនជាងមុនក្នុងអំឡុងវិបត្តិកូវីដ-១៩។

កិច្ចពិភាក្សាពេញអង្គស្តីពី «បញ្ហាប្រឈមក្នុងការរៀនសូត្រ និងការបោះបង់ការសិក្សារបស់កុមារក្នុងអំឡុងវិបត្តិកូវីដ-១៩ ៖ ករណីសិក្សាក្នុងខេត្តក្រចេះ» ពិភាក្សាពីបញ្ហាប្រឈមក្នុងការរៀនសូត្រ និងការបោះបង់ការសិក្សារបស់កុមារក្នុងខេត្តក្រចេះ អនាគតនៃការបង្រៀន និងស្វែងយល់ពីតួនាទីរបស់ភាគីពាក់ព័ន្ធក្នុងការបង្កើនការអប់រំកម្រិតបឋមសិក្សាប្រកបដោយគុណភាព។

## ខ្លឹមសារសង្ខេបនៃកិច្ចពិភាក្សា

ផ្អែកលើការស្ទង់មតិមួយដែលធ្វើឡើងដោយសមាគមខ្មែរដើម្បីអភិវឌ្ឍន៍តាមជនបទ - (ស.ខ.អ.ជ) ក្នុងឆ្នាំ ២០២០ ជាមួយសិស្សភាគច្រើនដែលដល់អាយុចូលរៀនបឋមសិក្សា និងមកពីគ្រួសារមានប្រាក់ចំណូលទាប ដែលតំណាងឱ្យសាលាបឋមសិក្សាចំនួន ១៥ ក្នុងខេត្តក្រចេះ សិស្សជាច្រើនលើកឡើងពីបញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀនសូត្រក្នុងអំឡុងពេលវិបត្តិកូវីដ-១៩។ បញ្ហាធំចំបងគឺការបិទសាលា ដែលតម្រូវឱ្យសិស្សរៀនតាមប្រព័ន្ធអនឡាញ។ កុមារជួបប្រទះបញ្ហាការសិក្សាដោយសារសេវាអ៊ីនធឺណិតយឺត និងកង្វះឧបករណ៍អេឡិចត្រូនិក (ស្មាតហ្វូន ឬ tablet) ព្រមទាំងចំណេះដឹងមានកម្រិតក្នុងការប្រើប្រាស់កម្មវិធីសិក្សាតាមអនឡាញ ដូចជា Telegram និង Google Meet។ កុមារទាំងនោះក៏លើកឡើងថា ការសិក្សាតាមអនឡាញមិនសូវមានភាពរស់រវើកដូចការរៀនក្នុងថ្នាក់ផ្ទាល់នោះទេ ដូច្នេះវាធ្វើឱ្យពួកគេមានអារម្មណ៍ធុញថប់ និងមិនសូវយកចិត្តទុកដាក់លើការសិក្សា។ គ្រូបង្រៀនកត់សម្គាល់ថា ពួកគាត់ត្រូវរៀនពីកម្មវិធីបង្រៀនតាមប្រព័ន្ធអនឡាញ ដែលការបង្រៀនតាមវិធីនេះមិនសូវមានប្រសិទ្ធភាព ព្រោះពួកគេមិនសូវមានចំណេះដឹង និងលំបាកក្នុងការចែករំលែកឯកសារមេរៀនជាមួយសិស្ស។ សេវាអ៊ីនធឺណិតគឺជាបញ្ហាចោទមួយទៀតនៅតាមសាលារៀនមួយចំនួន ដែលស្ថិតនៅតំបន់ដាច់ស្រយាល ដែលល្បឿនអ៊ីនធឺណិតយឺត និងមិនទៀងទាត់។ ដូច្នេះ វាបានបង្កើនអត្រាបោះបង់ការសិក្សា និងអត្រារៀនត្រួតថ្នាក់នៅកម្រិតបឋមសិក្សា។ ការស្ទង់មតិ នេះរកឃើញថា សិស្សបឋមសិក្សាប្រមាណ ៥%-៦% បានបោះបង់ការសិក្សា ដែលក្នុងនោះភាគច្រើនគឺជាសិស្សស្រី ហើយសិស្សចំនួន ១២,៧% រៀនត្រួតថ្នាក់ក្នុងអំឡុងពេលផ្ទុះឡើងនៃជំងឺកូវីដ-១៩។

ក្នុងអំឡុងពេលបិទសាលារៀន ក្រសួងអប់រំ យុវជន និងកីឡា បានដាក់បទប្បញ្ញត្តិជាច្រើនពាក់ព័ន្ធការបង្រៀនពីចម្ងាយ ដូចជា ការថតវីដេអូបង្រៀនទុកជាមុនសម្រាប់ចាក់ផ្សាយតាមប៉ុស្តិ៍ទូរទស្សន៍ និងកម្មវិធីទូរស័ព្ទចល័ត។ សំណៅឯកសារកិច្ចការផ្ទះក៏ត្រូវបានចែកជូនសិស្សក្នុងអំឡុងពេលបិទសាលារៀនផងដែរ។ គ្រូបង្រៀនត្រូវបានណែនាំពីរបៀបប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការបង្រៀន និងការប្រាស្រ័យទាក់ទងជាមួយសិស្ស។ គ្រូ និងនាយកសាលា គួរចុះទៅដល់ផ្ទះរបស់កុមារ ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ឧបករណ៍សិក្សាអនឡាញ ដូចជា ការតម្លើងកម្មវិធីក្នុងស្មាតហ្វូន និងការចែកម៉ាស់ អាល់កុលលាងដៃ និងសាប៊ូ។

ដើម្បីកែលម្អការសិក្សារបស់សិស្ស និងកាត់បន្ថយអត្រាបោះបង់ការសិក្សា ព្រមទាំងធានាថា ការបង្រៀនមានលក្ខណៈបរិយាបន្នជាងមុន គ្រូបង្រៀនគួរទទួលបានការគាំទ្រ និងការបណ្តុះបណ្តាលសម្រាប់ការបង្រៀនសិស្សមានពិការភាព ឧទាហរណ៍ សិស្សមានការលំបាកក្នុងការស្តាប់។ ការផ្តល់ការអប់រំពហុភាសាដើម្បីធានាថា កុមារជនជាតិភាគតិចមានឱកាសរៀនសូត្រដូចកុមារទូទៅដែរ។ ក្រៅពីនេះ ការពង្រឹងសមត្ថភាពរបស់គ្រូបង្រៀនលើជំនាញព័ត៌មានវិទ្យា ដូចជា ការប្រើប្រាស់កុំព្យូទ័រដើម្បីរក្សាទុកទិន្នន័យ និងរបៀបប្រើប្រាស់កម្មវិធីអនឡាញសម្រាប់ការបង្រៀន

[1] ការស្ទង់មតិខាងលើធ្វើឡើងជាមួយអ្នកចូលរួមចំនួន ៣១៦ នាក់ដែលជា សិស្សបឋមសិក្សា គ្រូបង្រៀន អាណាព្យាបាលសិស្ស អាជ្ញាធរមូលដ្ឋានមកពីសាលាបឋមសិក្សាចំនួន ១៥ នៅក្នុងខេត្តក្រចេះ។

និងការប្រាស្រ័យទាក់ទង ព្រោះវាអាចជួយដល់ពួកគេក្នុងការបន្សាំនឹងការបង្រៀនពីចម្ងាយបានកាន់តែងាយស្រួល និងកាន់តែឆាប់រហ័ស ក្នុងករណីមានជំងឺរាតត្បាតជាសកលនាពេលអនាគត។ ទន្ទឹមនឹងនេះ ការបង្កើនសមត្ថភាពអានរបស់សិស្ស ក៏ជាសមាសភាគដ៏សំខាន់ក្នុងការកាត់បន្ថយអត្រាបោះបង់ការសិក្សាផងដែរ។ កុមារដែលចេះអានស្ទាត់ លើកឡើងពីបំណងចង់រៀនបន្តជាងកុមារដែលមិនចេះអាន។ ការលើកទឹកចិត្តយុវជនឱ្យជួយដល់សិស្សវ័យក្មេងលើផ្នែកអំណាន។ ក្រៅពីនេះ ការបង្កើតមជ្ឈមណ្ឌលអំណាន ជាពិសេសនៅតាមសាលារៀនដែលកុមារលំបាកខ្លាំងផ្នែកអំណាន។ នាយកដ្ឋាន ឬមន្ទីរពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលគួរសហការគ្នាស្វែងរកធនធានជួយដល់កុមារដែលមិនសូវមានសម្ភារៈ ឯកសាររៀនសូត្រ និងមធ្យោបាយធ្វើដំណើរទៅសាលារៀន។








# ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើកិច្ចគាំពារ និងសុខុមាលភាពកុមារ ៖ ករណីសិក្សាពីខេត្តបាត់ដំបង




ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើកុមារ និងក្រុមគ្រួសារ មិនមែនមានត្រឹមតែការឆ្លងជំងឺប៉ុណ្ណោះទេ។ សាលារៀនបានបិទទ្វារ ហើយប្រាក់ចំណូលរបស់គ្រួសារក៏បានរងផលប៉ះពាល់ដែរ។ អ្នកដែលប្រឈមនឹងបញ្ហាខ្លាំងបំផុតគឺអ្នកដែលមានកម្រិតជីវភាពក្រោម ត្រឹម ឬលើសបន្ទាត់ភាពក្រីក្របន្តិច។ គ្រួសារជាច្រើនដែលរស់នៅក្នុងស្ថានភាពណែនតាន់តាប់ ដូចជា តំបន់សំណង់អនាធិបតេយ្យ ងាយរងគ្រោះដោយសារការផ្ទុះឡើងនៃវីរុស។ ក្នុងអំឡុងពេលវិបត្តិកូវីដ-១៩ កុមារកាន់តែងាយប្រឈមនឹងការរំលោភបំពាន អំពើហិង្សា និងការកេងប្រវ័ញ្ច និងការឈឺចាប់ផ្លូវចិត្តនៅពេលពួកគេមិនទទួលបានការថែទាំពីឪពុកម្តាយ ព្រោះឪពុកម្តាយមួយចំនួនបានធ្វើចំណាកស្រុកទៅរកការងារធ្វើនៅកន្លែងផ្សេង។

កុមារជាច្រើនងាយប្រឈមនឹងអំពើហិង្សា ដូចជា អំពើហិង្សាផ្លូវភេទ ការរំលោភបំពានផ្លូវកាយ និងផ្លូវចិត្ត និងការមើលឃើញអំពើហិង្សាដែលបង្កឡើងដោយឪពុកម្តាយ។ បញ្ហាទាំងនេះ អាចបណ្តាលមកពីអ្នកថែទាំ និងសមាជិកគ្រួសារដែលជាមនុស្សពេញវ័យដទៃទៀត មានបញ្ហាស្ត្រេស ទុក្ខព្រួយ និងមិនទទួលបានការគាំទ្រ ហើយអារម្មណ៍ផ្សារភ្ជាប់ខ្លួនទៅនឹងសហគមន៍ក៏មិនមាន ចំណែកឯការប្រើប្រាស់យន្តការទប់ទល់នឹងវិបត្តិ (ការប្រើប្រាស់គ្រឿងស្រវឹង ជាដើម) ក៏មិនអាចជួយអ្វីបាន។ បន្ថែមពីលើនេះ ផលប៉ះពាល់ទៅលើសង្គមសេដ្ឋកិច្ចដែលបណ្តាលមកពីជំងឺកូវីដ-១៩ក៏បង្កឱ្យមានហានិភ័យផ្សេងទៀតដល់សិទ្ធិទទួលបានការអប់រំរបស់កុមារក៏ដូចជាសុខុមាលភាព និងការការពាររបស់ពួកគេផងដែរ។ ការរៀនតាមប្រព័ន្ធអនឡាញ (ការចំណាយពេលកាន់តែច្រើនតាមប្រព័ន្ធអនឡាញ) ក៏អាចធ្វើឱ្យកុមាររឹតតែប្រឈមនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ។

កិច្ចពិភាក្សាស្តីពី «ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើកិច្ចគាំពារ និងសុខុមាលភាពកុមារៈ ករណីសិក្សាពីខេត្តបាត់ដំបង» ពិភាក្សាគំហើញពីការស្រាវជ្រាវដែលអាចដាក់បញ្ចូលទៅក្នុងផែនការរបស់អាជ្ញាធរមូលដ្ឋាន មន្ទីរ អង្គការសង្គមស៊ីវិល ក្រុមប្រឹក្សាឃុំ និងសហគមន៍មូលដ្ឋាន ដើម្បីគាំទ្រដល់កុមារដែលរងផលប៉ះពាល់ ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ។





## ខ្លឹមសារសង្ខេបនៃកិច្ចពិភាក្សា

ក្នុងឆ្នាំ ២០២១ សមាគមកុមាររីករាយបានធ្វើការសិក្សាមួយស្តីពី «ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើកិច្ចគាំពារ និងសុខុមាលភាពកុមារ» ក្នុងភូមិចំនួន ១០ ក្នុងខេត្តបាត់ដំបង ជាមួយឪពុកម្តាយ និងអ្នកថែទាំចំនួន ១៥០នាក់ និងកុមារចំនួន ១៥០នាក់ (អាយុ១១ ដល់១៧ឆ្នាំ)។ ទោះបីជាសំណាកតូច ប៉ុន្តែការសិក្សានេះរកឃើញថា ជំងឺកូវីដ-១៩បានបង្កផលប៉ះពាល់លើអ្នកថែទាំ និងកុមារ ដោយពួកគេបានលើកឡើងពីអារម្មណ៍តានតឹង និងថប់បារម្ភ។ គ្រួសារប្រមាណ ៩០% បានបាត់បង់ការងារដោយសារការរឹតត្បិតការធ្វើដំណើរ និងមានការកើនឡើងនៃអំពើហិង្សាក្នុងគ្រួសារ។

ការបិទសាលារៀនបានបង្កផលប៉ះពាល់យ៉ាងខ្លាំងលើអ្នកចូលរួមក្នុងការស្ទង់មតិ។ ឪពុកម្តាយភាគច្រើនដឹងថា កូនរបស់ពួកគាត់អាចប្រើប្រាស់ស្មាតហ្វូនដើម្បីរៀនតាមអនឡាញ ប៉ុន្តែពួកគាត់មិនសូវមានចំណេះដឹងក្នុងការការពារកូនពីការរំលោភបំពានតាមអនឡាញ ឬមូលដ្ឋានគ្រឹះនៃសុវត្ថិភាពតាមប្រព័ន្ធអនឡាញនោះទេ។ ក្រៅពីនេះ ការសិក្សានេះរកឃើញថា កុមារដែលជាអ្នកតបសម្ភាសន៍ចំនួន ៦០% មានអារម្មណ៍មិនសប្បាយចិត្តជាងពេលមុនវិបត្តិកូវីដ-១៩ ហើយកុមារចំនួន ៤០% មានអារម្មណ៍អស់សង្ឃឹម។ អ្នកថែទាំ ឬឪពុកម្តាយក៏កត់សម្គាល់ផងដែរនូវការប្រែប្រួលទម្លាប់គេងរបស់កុមារ និងការរំខានដល់ដំណេករបស់កុមារ។ កុមារខ្លះមានឥរិយាបទឆេវឆាវជាងមុន អសកម្ម និងមិនសូវប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ។

យោងតាមវាគ្មិនម្នាក់ដែលធ្វើការងារពាក់ព័ន្ធនឹងបញ្ហារបស់កុមារ នៅពេលមនុស្សកាន់តែច្រើនរស់នៅក្នុងកន្លែងតែមួយ លទ្ធភាពទទួលរងការរំលោភបំពានដែលប៉ះពាល់ដល់សុខុមាលភាពរបស់កុមារក៏កាន់តែខ្ពស់។ ការប្រឈមមុខជាមួយបញ្ហានេះ ទាមទារការសហការគ្នាពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ ដូចជា រដ្ឋបាលថ្នាក់មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងគ្រួសារផ្ទាល់។

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ បានរៀបចំកិច្ចប្រជុំជាប្រចាំដើម្បីស្វែងយល់ពីសុខុមាលភាពរបស់កុមារដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ និងពិភាក្សារកដំណោះស្រាយតាមប្រព័ន្ធអ៊ីនធឺណិតជាមួយថ្នាក់ស្រុក និងថ្នាក់ឃុំ។ ជាលទ្ធផល រដ្ឋាភិបាលថ្នាក់ក្រោមជាតិបានធ្វើការជាមួយភាគីពាក់ព័ន្ធផ្សេងៗដើម្បីផ្តល់អាហារ ផ្គត់ផ្គង់សម្ភារៈសំខាន់ៗ និងសម្ភារៈសិក្សាដល់គ្រួសារងាយរងគ្រោះ។ ក្រៅពីនេះ សកម្មភាពបង្កើនការយល់ដឹងជាមួយសហគមន៍ ដូចជា ការបង្កើនការយល់ដឹងលើប្រធានបទស្តីពីការប្រើប្រាស់ភាសាលើកទឹកចិត្តជាមួយកុមារតូច ឥរិយាបថវិជ្ជមាននៅផ្ទះ និងសាលារៀន របៀបទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងសារៈសំខាន់នៃការគាំទ្រផ្លូវចិត្តក្នុងគ្រួសារ។



សម្រាប់ជាគន្លឹះឆ្ពោះទៅមុខ ភាគីពាក់ព័ន្ធមកពីស្ថាប័នរដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាលគួរសហការគ្នាគាំទ្រដល់កុមារ និងគ្រួសារងាយរងគ្រោះ។ ការសិក្សាបន្ថែមទៀតគួររៀបចំដើម្បីវាយតម្លៃការអនុវត្តកម្មវិធីគាំទ្រដោយភាគីពាក់ព័ន្ធផ្សេងៗ និងដាក់ចេញបទអន្តរាគមន៍ដែលអាចដោះស្រាយបញ្ហាទាំងនេះបានល្អបំផុតក្នុងរយៈពេលវែង។

## អ្នកសម្របសម្រួល



លោក ឃុន ប៊ុនលី
នាយក
អង្គការខ្មែរដើម្បីការអប់រំ



លោកជំទាវ ផាវ៉ាន់ សាកឿត
សមាជិកក្រុមប្រឹក្សាខេត្ត និងជាអនុប្រធាន
គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ
ខេត្តបាត់ដំបង

## វាគ្មិនកិត្តិយស



លោកស្រី ព្រហ្ម គឹមឆេង
នាយិកាប្រតិបត្តិ
សមាគមកុមាររីករាយ



លោក ហោ កុសល្យ
ប្រធានអភិវឌ្ឍន៏គម្រោង និងទំនាក់ទំនងជាន់ខ្ពស់នៃអង្គការមូលនិធិហាការអន្តរជាតិ



## សេចក្តីសន្និដ្ឋាន

វេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ ស្តីពី «សារៈសំខាន់នៃការស្រាវជ្រាវនៅថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩» ចូលរួមដោយភាគីពាក់ព័ន្ធចំនួន ៥០ នាក់ ដូចជា តំណាងរដ្ឋបាលថ្នាក់ក្រោមជាតិចាប់ពីថ្នាក់ខេត្តរហូតដល់ថ្នាក់ឃុំ អ្នក-ស្រាវជ្រាវ សង្គមស៊ីវិល អ្នកតាក់តែងគោលនយោបាយ អ្នកជំនាញផ្នែកគោលនយោបាយ និងសិស្សានុសិស្សមកពីខេត្តបាត់ដំបង ក្រចេះ និងស្ទឹងត្រែង។ វេទិកានេះពិភាក្សាពីសារៈសំខាន់នៃទិន្នន័យដែលទទួលបានពីសហគមន៍មូលដ្ឋានសម្រាប់គាំទ្រដល់រដ្ឋាភិបាលថ្នាក់ជាតិក្នុងការដោះស្រាយផលប៉ះពាល់នៃជំងឺរាតត្បាតសកលកូវីដ-១៩ និងករណីសិក្សាចំនួនបី ស្តីពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើជនជាតិដើមភាគតិច ការរៀនសូត្ររបស់កុមារ និងកិច្ចគាំពារកុមារ។

វេទិកាគោលនយោបាយថ្នាក់ខេត្តនេះជាព្រឹត្តិការណ៍ចម្បងមួយរបស់កម្មវិធីពន្លកចំណេះ ដែលគាំទ្រដល់អង្គការតាមមូលដ្ឋានផ្សេងៗ ដើម្បីស្រាវជ្រាវ និងប្រមូលទិន្នន័យទាន់ពេលវេលា ដែលឆ្លើយតបនឹងបញ្ហាចំពោះមុខរបស់ប្រជាជនមូលដ្ឋានក្នុងអំឡុងពេលវិបត្តិកូវីដ-១៩។

ខាងក្រោមនេះជាមេរៀនសំខាន់ៗមួយចំនួន រួមមាន៖

- ទិន្នន័យពីថ្នាក់សហគមន៍ និងថ្នាក់ក្រោមជាតិ មានសារៈសំខាន់សម្រាប់រដ្ឋាភិបាលថ្នាក់ជាតិក្នុងការតាក់តែងគោលនយោបាយ និងរៀបចំកម្មវិធីអន្តរាគមន៍ ក៏ដូចជាវាស់វែងវឌ្ឍនភាពតាមរយៈការអនុវត្ត។
- ការកែលម្អឌីជីថលភាវូបនីយកម្មបន្ថែមទៀតសម្រាប់ការប្រមូលទិន្នន័យនៅថ្នាក់មូលដ្ឋាន ដើម្បីធានាសុក្រឹតភាព ក៏ដូចជាសន្សំសំចៃពេលវេលា និងធនធាន។
- ការផ្តោតអាទិភាពលើក្រុមដែលត្រូវបានគេមើលរំលង ដើម្បីឱ្យទិន្នន័យបែបបរិមាណ និងទិន្នន័យបែបគុណភាពដែលប្រមូលបាន ឆ្លើយតបនឹងតម្រូវការជាក់លាក់របស់ពួកគេ។
- មេរៀនជាច្រើនពីបទពិសោធន៍របស់កម្ពុជាក្នុងអំឡុងពេលវិបត្តិកូវីដ-១៩ គួរយកទៅអនុវត្ត ដើម្បីឱ្យសហគមន៍ និងអង្គការ ឬស្ថាប័ននានាអាចត្រៀមខ្លួនទប់ទល់នឹងជំងឺរាតត្បាតសកល ឬការបង្អាក់ដល់ការទទួលបានការថែទាំសុខភាព និងការអប់រំនាពេលអនាគត។
- កិច្ចសហការក្នុងចំណោមភាគីពាក់ព័ន្ធផ្សេងៗដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាថា អន្តរាគមន៍បែបបរិយាបន្ន និងការស្វែងរកធនធាន។
- ការអនុវត្តកម្មវិធី ឬអន្តរាគមន៍ថ្នាក់ជាតិឱ្យបន្សុីគ្នានឹងបរិបទមូលដ្ឋាន មានសារៈសំខាន់ណាស់ក្នុងការធានាប្រសិទ្ធភាពនៃការអនុវត្ត និងភាពអាចសម្រេបតាមបានដោយសហគមន៍ផ្ទាល់៕









# របៀបវារៈ

វេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ
សារៈសំខាន់នៃការស្រាវជ្រាវនៅថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩
កាលបរិច្ឆេទ ៖ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២២
ទីតាំង ៖ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ព្រះរាជាណាចក្រកម្ពុជា

| ម៉ោង | របៀបវារៈ | កំណត់សម្គាល់ |
| --- | --- | --- |
| ៨:០០ – ៨:៣០ | ការចុះឈ្មោះ | អង្គការមូលនិធិអាស៊ី |
| ៨:៣០ – ៨:៣៥ | ការចាប់ផ្តើមវេទិកា និងគោរពភ្លេងជាតិ | ពិធីករ |
| ៨:៣៥ – ៨:៤៥ | សុន្ទរកថាស្វាគមន៍ | លោកស្រី មេឡូនី លីនប៊ីកតំណាង អង្គការមូលនិធិអាស៊ីប្រចាំកម្ពុជា |
| ៨:៤៥ – ៩:០០ | សុន្ទរកថាបើកកម្មវិធី | លោក **Andreas Zurbrugg** ឯកអគ្គរដ្ឋទូតរង ស្ថានទូតអូស្ត្រាលី ប្រចាំ កម្ពុជា |
| ៩:០០ – ៩:១៥ | សុន្ទរកថាគន្លឹះ | ឯកឧត្តម ខូយ រីដា អភិបាល នៃគណៈអភិបាល ខេត្តពោធិ៍សាត់ (អតីតអភិបាលរង ខេត្តបាត់ដំបង) |
| ៩:១៥ – ៩:៣០ | ការថតរូបជាក្រុម | ក្រុមការងារកម្មវិធីពន្លកចំណេះ |
| ៩:៣០ – ១០:០០ | សម្រាក | |
| ១០:០០ – ១១:៣០ | **ការចាប់ផ្តើមកិច្ចពិភាក្សាពេញអង្គ ៖**<br><br>ការប្រើប្រាស់ទិន្នន័យដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្ត៖ការប្រើប្រាស់ទិន្នន័យរបស់រដ្ឋបាលមូលដ្ឋានដើម្បីឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ក្នុងអំឡុងពេលវិបត្តិកូវីដ-១៩<br><br>សំណួរ-ចម្លើយ | **វាគ្មិន ៖**<br>- ឯកឧត្តម អ៊ីវ កុសល ប្រធានមន្ទីរផែនការ ខេត្តបាត់ដំបង<br>- លោក ជ័យ សម្បត្តិផល្លា ប្រធាននាយកដ្ឋានវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) |

| | | |
|---|---|---|
| | | - លោក សា រឿន អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបាត់ដំបង<br><br>**អ្នកសម្របសម្រួល ៖**<br>- លោក ម៉ែន ពិចិត្រ ប្រធានកម្មវិធី អង្គការមូលនិធិអាស៊ី |
| ១១:៣០ – ១៣:១៥ | សម្រាក | |
| ១៣:១៥– ១៤:៣០ | **កិច្ចពិភាក្សាពេញអង្គ ៖**<br><br>ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ ទៅលើសេដ្ឋកិច្ចសង្គមរបស់ប្រជាជនក្នុងតំបន់ និងសហគមន៍ជនជាតិដើមភាគតិច ៖ ករណីសិក្សាពីខេត្តស្ទឹងត្រែង<br><br>សំណួរ-ចម្លើយ | **វាគ្មិន ៖**<br>- លោក ញ៉ែម វណ្ណយុត្តិ នាយករដ្ឋបាលខេត្តស្ទឹងត្រែង<br>- លោក សែត ពិសិដ្ឋ អនុប្រធានការិយាល័យអប់រំ មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្ទឹងត្រែង<br>- លោក ប៉ោ ណារិទ្ធ ទីប្រឹក្សាអង្គការភូមិខ្ញុំ<br><br>**អ្នកសម្របសម្រួល ៖**<br>- លោក ហ៊ុន សុធា អ្នកសម្របសម្រួលកម្មវិធី សមាគមខ្មែរដើម្បីអភិវឌ្ឍន៍តាមជនបទ |
| ១៤:៣០ – ១៤:៤៥ | សម្រាក | |
| ១៤:៤៥ – ១៦:០០ | **កិច្ចពិភាក្សាពេញអង្គ ៖**<br><br>ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើការរៀនសូត្រ និងការបោះបង់ការសិក្សារបស់កុមារ ៖ ករណីសិក្សាពីខេត្តក្រចេះ<br><br>សំណួរ-ចម្លើយ | **វាគ្មិន ៖**<br>- លោក ជឿង មនោរម្យ អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុកឆ្លូង ខេត្តក្រចេះ<br>- លោក អន សិទ្ធី នាយកសាលាបឋមសិក្សាភូមិកណ្ដាល<br>- លោក អ៊ុក យុទ្ធ នាយកប្រតិបត្តិ សមាគមខ្មែរដើម្បីអភិវឌ្ឍន៍តាមជនបទ |

| | | |
|---|---|---|
| | | **អ្នកសម្របសម្រួល ៖**<br>- លោក ហ៊ុន សុធា អ្នកសម្រប សម្រួលកម្មវិធី សមាគមខ្មែរ ដើម្បីអភិវឌ្ឍន៍តាមជនបទ |
| ១៦.០០ – ១៧:១៥ | **កិច្ចពិភាក្សាពេញអង្គ ៖**<br><br>ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើកិច្ចគាំពារកុមារ៖ ករណីសិក្សាពីខេត្តបាត់ដំបង<br><br>សំណួរ-ចម្លើយ | **វាគ្មិន ៖**<br>- លោកជំទាវ សាគឿត ផាវ៉ាន់ អនុប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ខេត្តបាត់ដំបង<br>- លោកស្រី ព្រហ្ម គឹមឆេង នាយកប្រតិបត្តិសមាគមកុមាររីករាយ<br>- លោក ហោ កុសល្យ អ្នកគ្រប់គ្រងកម្មវិធីជាន់ខ្ពស់នៃអង្គការមូលនិធិហាការអន្តរជាតិ<br><br>**អ្នកសម្របសម្រួល ៖**<br>- លោក យុន ប៊ុនលី នាយក អង្គការខ្មែរដើម្បីការអប់រំ |
| ១៧:១៥ – ១៧:៣០ | សុន្ទរកថាបិទកម្មវិធី | លោក **Andreas Zurbrugg** ឯកអគ្គរដ្ឋទូតរង ស្ថានទូតអូស្រ្តាលី ប្រចាំប្រទេសកម្ពុជា |
| ១៧:៣០ | ចប់កម្មវិធី | |

កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា គឺជាកម្មវិធីមួយមានរយៈពេលបួនឆ្នាំ ដែលផ្តួចផ្តើមឡើងដោយអង្គការមូលនិធិអាស៊ី ក្នុងគោលបំណងរួមចំណែកពង្រឹងសមត្ថភាពស្ថាប័នស្រាវជ្រាវ ដើម្បីលើកកម្ពស់ការស្រាវជ្រាវ ប្រកបដោយគុណភាព ដែលអាចប្រើប្រាស់ជាទិន្នន័យគាំទ្រដល់ការវិភាគ និងការពិភាក្សាអំពីគោលនយោបាយសាធារណៈនៅកម្ពុជា ក្រោមការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី។

**អង្គការមូលនិធិអាស៊ី**

ផ្ទះលេខ៥៩ ផ្លូវ២៤២ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ponlokchomnes@asiafoundation.org

(+៨៥៥) ០២៣ ២១០ ៤៣១

https://policypulse.org/

Australian Aid

ពន្លកចំណេះ

The Asia Foundation